**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ ១៤៧...... ប្រក- ដនស/ជសហ

ភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពី
## ការបង្កើត គណៈកម្មាធិការ កំណត់បុរេលក្ខណៈ សម្បត្តិ វាយតម្លៃ ប្រគល់កិច្ចសន្យា (PEAC) និង បង្កើត អង្គភាពលទ្ធកម្ម (PU) របស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ ន.ស / រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ០៣ អ.ន.ក្រប.ក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការប្រគល់ទីតាំង និងអង្គភាពចំណុះអោយមកស្ថិតនៅក្រោម ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦០ អ.ន.ក្រប.ក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង លទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៣១៩ សហវ.មប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តវិធាន និង បទប្បញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញការចាំបាច់ របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

## សម្រេច

ប្រការ ១ : បង្កើតគណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា ( PEAC ) របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋលេខាធិការក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ប្រធាន |
| ២-ឯកឧត្តម **កើត សារ៉េត** | អនុរដ្ឋលេខាធិការក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | អនុប្រធាន |
| ៣-លោក **ឆា ចំនួលីជា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |

៤-លោក **នុត ពុធដារ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

៥-លោក **ង៉ូវ ទុន្នី** ប្រធាននាយកដ្ឋានស្ថិតិផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច សមាជិក

៦-លោក **តាន់ សេងហៀង** អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច សមាជិក

៧-លោកស្រី **ឡេង ហ៊ាង** ប្រធានអង្គភាពលទ្ធកម្ម (PU) លេខាធិការ

គណៈកម្មាធិការនេះមានភារៈកិច្ចទទួលខុសត្រូវ ក្នុងការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃសំណើដេញថ្លៃ និង ប្រគល់កិច្ចសន្យា របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

**ប្រការ ២** : បង្កើតអង្គភាពលទ្ធកម្ម (PU) របស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលមានសមាសភាព ដូចខាងក្រោម :

១-លោកស្រី **ឡេង ហ៊ាង** ប្រធានការិយាល័យគ្រប់គ្រងផែនការសេដ្ឋកិច្ច ប្រធាន

២-លោក **ហាក់ ហ៊ុន** អនុប្រធាន ការិយាល័យគណនេយ្យ អនុប្រធាន

៣-លោកស្រី **កុសល សុទិចារ** ប្រធាន ការិយាល័យគណនេយ្យ សមាជិក

៤-លោក **ស៊ុត បូរ៉េត** ប្រធានការិយាល័យគ្រប់គ្រង និង ផ្គត់ផ្គង់ សមាជិក

៥-លោក **ម៉ិន ទុន្តា** អនុប្រធានការិយាល័យ កិច្ចការវិនិយោគ សមាជិក

៦-លោក **លុក សុវណ្ណា** មន្ត្រីការិយាល័យ គណនេយ្យ សមាជិក

**ប្រការ ៣** : ប្រធានអង្គភាពលទ្ធកម្ម (PU) មានតួនាទីជាលេខាធិការ របស់គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា (PEAC) ។

**ប្រការ ៤** : អង្គភាពលទ្ធកម្ម (PU) របស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មានភារកិច្ច :

១- រៀបចំឯកសារចាំបាច់ (រួមទាំងឯកសារដេញថ្លៃ ដោយប្រកួតប្រជែង) សំរាប់គ្រប់កិច្ចលទ្ធកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយធ្វើការពិគ្រោះ ឬ ដោយមានការ ឧបត្ថម្ភពីអង្គភាពពាក់ព័ន្ធ ។

២- រៀបចំផ្សព្វផ្សាយអញ្ជើញ អោយចូលរួមដេញថ្លៃ នៅក្នុងសារពតិមានជាតិ ឬ បរទេស និង ផ្ញើលិខិតសាកសួរថ្លៃទៅអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ។

៣- បញ្ជូនឯកសារដែលដេញថ្លៃ ទៅអោយភាគី ដែលចង់បានឯកសារទាំងនេះ ។

៤- ទទួលសំណើរដេញថ្លៃ ឬ តារាងតម្លៃ ពីអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការដែលចូលរួមព្រមទាំងធ្វើការពិនិត្យ ភាពសមស្រប នៃសំណើដេញថ្លៃ ។

៥- បញ្ជូនការងារលទ្ធកម្ម ដែលចាំបាច់ ទៅនាយកដ្ឋានលទ្ធកម្មសាធារណៈ ហើយរៀបចំ និង បញ្ជូនទំរង់របាយការណ៍ នៃការដេញថ្លៃ ឬ ទំរង់របាយការណ៍លទ្ធកម្ម ។

៦- ផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ ព្រមទាំងរៀបចំចុះហត្ថលេខាលើកិច្ចសន្យាដែលបាន អនុម័តរួចហើយ ។

៧- ត្រួតពិនិត្យការប្រគល់-ទទួល ទំនិញ និង សំណង់ ហើយបញ្ជូនសំណុំឯកសារចាំបាច់ ទៅអង្គភាពមានសមត្ថកិច្ច ដើម្បីធ្វើការទូទាត់ ។

៨- អនុវត្តអោយបានម៉ត់ចត់ នូវវិធាន និង បទបញ្ញត្តិស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ( ប្រកាសលេខ ៣១៩ ) ក្នុងការអនុវត្តនី កិច្ចលទ្ធកម្ម ជាពិសេសការកំណត់អោយបានត្រឹមត្រូវ នូវ វិធីសាស្ត្រ និង នីតិវិធីលទ្ធកម្ម ។

៩- កំណត់ពេលធ្វើការក្នុងការបំពេញកិច្ចលទ្ធកម្ម និងៈ គោរពនូវពេលវេលាដែលបានកំណត់ ។

១០- ពិនិត្យតាមដានដោយម៉ត់ចត់ នូវរាល់សកម្មភាពការងារលទ្ធកម្ម ជាមួយក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

__ប្រការ ៥__ : រាល់ប្រកាស ឬសេចក្តីសំរេចណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

__ប្រការ ៦__ : នាយកខុទ្ទកាល័យ និង អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ . អស់លោក ដែលមានឈ្មោះក្នុងប្រការ១ និង ប្រការ ២ ត្រូវអនុវត្តនីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

__ចំលងជូន__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- នាយកដ្ឋាន លទ្ធកម្មសាធារណៈ
- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- ឯកសារ- កាលប្បវត្តិ